actionaid

# របាយការណ៍តាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី

២០១៩



## សេចក្តីសង្ខេបនៃរបាយការណ៍

ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី នៅថ្ងៃទី២០ កក្កដា ២០១៧ បានចុះហត្ថលេខាប្រកាសឲ្យអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី។ ក្រមប្រតិបត្តិនេះមាន១៥ប្រការ និងមានគោលបំណងទប់ស្កាត់ការយកករណីហិង្សាលើស្ត្រី ធ្វើជាព័ត៌មានកម្សាន្តសប្បាយ និងដើម្បីកែប្រែឥរិយាបទសង្គមក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី។

បន្ទាប់ពីក្រមប្រតិបត្តិនេះត្រូវបានដាក់ចេញ អង្គការអាក់សិនអេតកម្ពុជា បានចូលរួមចំណែកយ៉ាងសកម្មជាមួយក្រសួងទាំងពីរ ដើម្បីធ្វើការផ្សព្វផ្សាយពីក្រមប្រតិបត្តិនេះទៅដល់ អ្នកសារព័ត៌មាន និងធ្វើការតាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីជាបន្តបន្ទាប់។

លទ្ធផលនៃការតាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ធ្វើឡើងដោយក្រុមការងារបច្ចេកទេសនៃអង្គការអាក់សិនអេតកម្ពុជា បង្ហាញថា រយៈពេល៩ខែ ឆ្នាំ២០១៩ ចាប់តាំងពីខែមករា ដល់ខែកញ្ញា ស្ថាប័នព័ត៌មានចំនួនបួន បានចូលរួមរាយការណ៍ករណីហិង្សាលើស្ត្រីច្រើនជាងគេលើបណ្តាញសង្គមហ្វេសប៊ុក នោះគឺអរិយធម៌ (២៨ករណី) KBN News (២៣ករណី) កោះសន្តិភាព (២៣ករណី) និង TVFB (មាន២០ករណី)។

ជាការល្អដែលស្ថាប័នព័ត៌មានទាំងបួនចូលរួមសកម្មក្នុងការរាយការណ៍ករណីអំពើហិង្សាលើស្ត្រី ប៉ុន្តែក្រោយធ្វើការវិភាគ បានរកឃើញថា ស្ថាប័នព័ត៌មានទាំងបួនខាងលើ នៅមិនទាន់ប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួន ទៅតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីនៅឡើយទេ។ ជាក់ស្តែង ស្ថាប័នព័ត៌មានទាំងបួនខាងលើ មិនគោរពសិទ្ធិឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះ (៨៥% -១០០%) បន្ទោសជនរងគ្រោះ ឬយកលេសឱ្យជនប្រព្រឹត្ត (១៨% -៣៣%) យកការរាយការណ៍អំពើហិង្សាលើស្ត្រីជាការលេងសើច (៧% -៣៨%)។

ផ្អែកតាមរបាយការណ៍នេះ អង្គការអាក់សិនអេតកម្ពុជា សូមលើកឡើងនូវអនុសាសន៍សំខាន់ៗសម្រាប់ស្ថាប័នសារពត៌មានទាំងបួន ដូចជា៖ ត្រូវបង្កើនការយល់ដឹងរបស់អ្នករាយការណ៍ ព័ត៌មាន អ្នកអានព័ត៌មាន និងនិពន្ធនាយក អំពីឫសគល់នៃអំពើហិង្សាលើស្ត្រី, បញ្ឈប់ការបង្ហាញនូវអត្តសញ្ញាណ ឬការបំពានលើសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ, បញ្ឈប់ការស្តីបន្ទោសលើជនរងគ្រោះ, បញ្ឈប់ការរកលេសឱ្យជនប្រព្រឹត្ត, និងបញ្ឈប់ការយកករណីអំពើហិង្សាមករាយការណ៍ជាលក្ខណៈលេងសើច។

អង្គការអោក់សិនអេតកម្ពុជា មានជំនឿមុតមាំថា អ្នកសារព័ត៌មាន មានតួនាទីលើកកម្ពស់ការយល់ដឹង និងកែប្រែឥរិយាបថសង្គមឱ្យប្រសើរឡើង ហើយមិនគួរដើម្បីប្រជាប្រិយភាព បណ្តោយឱ្យអ្នកអានអូសទាញខ្លួនឱ្យធ្វើខុសក្រមសីលធម៌វិជ្ជាជីវៈនោះទេ។

ព្រមជាមួយគ្នានេះ អង្គការអោក់សិនអេតកម្ពុជា សូមទទូចឱ្យអ្នកសារព័ត៌មាន នៅពេលរាយការណ៍ករណីអំពើហិង្សាលើស្ត្រី ត្រូវដកស្រង់មតិយោបល់ពីស្ថាប័នជំនាញពាក់ព័ន្ធ ឬអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យនេះ ដើម្បីឱ្យសាធារណជន បានយល់ថាបញ្ហាអំពើហិង្សាលើស្ត្រីមិនមែនជាបញ្ហាឯកជនដែលកើតតែលើអ្នកដទៃនោះទេ។ ផ្ទុយទៅវិញវាជាបញ្ហារួម ជាការទទួលខុសត្រូវរបស់សង្គមទាំងមូលក្នុងការរកយុត្តិធម៌ឱ្យជនរងគ្រោះ និងរកវិធានការទប់ស្កាត់និងលុបបំបាត់។

## សេចក្តីលម្អិតនៃរបាយការណ៍

### ១. គោលបំណងនៃរបាយការណ៍

ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ បានចេញនូវប្រកាសរួមមួយស្តីពី «ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី» ក្នុងគោលបំណងផ្សព្វផ្សាយដល់អ្នកសារព័ត៌មានទាំងអស់នូវអ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើនៅពេលរាយការណ៍ព័ត៌មានករណីអំពើហិង្សាលើស្ត្រី។ អង្គការអាក់សិនអេតកម្ពុជា ក៏បានចូលរួមនៅក្នុងក្រុមការងារបច្ចេកទេសក្នុងការរៀបរៀងក្រមប្រតិបត្តិនេះផងដែរ។ បន្ទាប់ពីក្រមប្រតិបត្តិនេះត្រូវបានដាក់ចេញ អង្គការអាក់សិនអេតកម្ពុជាបានចូលរួមចំណែកជាមួយក្រសួងទាំងពីរ ដើម្បីធ្វើការផ្សព្វផ្សាយពីក្រមប្រតិបត្តិនេះទៅដល់អ្នកសារព័ត៌មាន និងធ្វើការតាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីជាបន្តបន្ទាប់។

របាយការណ៍នេះបង្ហាញពីលទ្ធផលនៃការតាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រីក្នុងរយៈពេល៩ខែក្នុងឆ្នាំ២០១៩ រាប់ពីខែមករាដល់ខែកញ្ញា។ របាយការណ៍នេះផ្តោតលើការរាយការណ៍ព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គមហ្វេសប៊ុក ដោយយល់ឃើញថាប្រជាពលរដ្ឋកម្ពុជាជាទូទៅនិយមអានព័ត៌មានតាមហ្វេសប៊ុក ជាងការអានកាសែត ស្តាប់វិទ្យុ ឬមើលទូរទស្សន៍។ ដូចនេះការផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធហ្វេសប៊ុកជះឥទ្ធិពលខ្លាំងលើប្រជាពលរដ្ឋកម្ពុជា ប្រសិនការរាយការណ៍នោះមិនគោរពតាមក្រមប្រតិបត្តិនេះទេ។ គួរកត់សម្គាល់ដែរថាប្រព័ន្ធផ្សព្វផ្សាយទាំងនេះអាចមានខ្លះបានចុះបញ្ជីជាមួយក្រសួងព័ត៌មាន និងខ្លះទៀតអាចមិនមានការចុះបញ្ជីនោះទេ ប៉ុន្តែក្រុមការងារតាមដានរបស់អង្គការអាក់សិនអេតកម្ពុជាមិនមានព័ត៌មានអំពីការចុះបញ្ជីនោះទេ។

របាយការណ៍នេះមានគោលបំណងរួមចំណែកក្នុងការបង្ហាញពីស្ថានភាពអំពើហិង្សាលើស្ត្រីនៅកម្ពុជា និងស្ថានភាពក្រមសីលធម៌វិជ្ជាជីវៈរបស់អ្នកសារព័ត៌មាននៅតាមបណ្តាញសង្គមហ្វេសប៊ុក ក្នុងការរាយការណ៍អំពើហិង្សាលើស្ត្រី ដើម្បីជាមូលដ្ឋានភស្តុតាងសម្រាប់ក្រសួងទាំងពីរ ធ្វើការឆ្លើយតបដើម្បីរួមចំណែកលុបបំបាត់អំពើហិង្សាលើស្ត្រីនៅកម្ពុជា។

### ២. ធនធានសម្រាប់ការងារតាមដាននិងចងក្រងរបាយការណ៍នេះ

ការងារតាមដានការរាយការណ៍ព័ត៌មានគឺធ្វើឡើងប្រចាំថ្ងៃដោយបុគ្គលិកហាត់ការនៃអង្គការអាក់សិនអេតកម្ពុជា មានប្អូនស្រី ខៀវ សុខកញ្ញា និង បន្ទាប់មកមានប្អូនស្រី ម៉ៅ ហ្គិចឡេង ដែលជាទូទៅប្រើពេលវេលាមួយម៉ោងក្នុង១ថ្ងៃ សម្រាប់ស្រាវជ្រាវ អាន និងបញ្ចូលទិន្នន័យ។ ការវិភាគទិន្នន័យព័ត៌មានដែល

ប្រមូលបាន និងការចងក្រងជារបាយការណ៍ធ្វើឡើងដោយ បុគ្គលិកដែលជាអ្នកសម្របសម្រួលយុទ្ធនាការ និងបុគ្គលិកផ្នែកគុណភាពកម្មវិធី និងផ្នែកទំនាក់ទំនង។

## ៣. លទ្ធផលនៃការតាមដានការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី

### ៣.១. ប្រភពព័ត៌មាន

ព័ត៌មានដែលក្រុមការងារបានអានសរុបចំនួន២២ប្រភពដែលបានរាយការណ៍ព័ត៌មានករណីអំពើហិង្សាលើស្ត្រីនៅលើបណ្ដាញសង្គមហ្វេសប៊ុក ក្នុងចន្លោះពីខែមករាដល់ខែកញ្ញា ឆ្នាំ២០១៩។ ក្នុងនោះ ប្រភពព័ត៌មានដែលរាយការណ៍ពីករណីអំពើហិង្សាលើស្ត្រីញឹកញាប់ជាងគេមានចំនួនបួនគឺ អរិយធម៌ (Arey News) ២៨ករណី ព័ត៌មានទាន់ហេតុការណ៍ (Khmer Breaking News) ២៣ករណី កោះសន្តិភាព (Koh Santepheap) ២១ករណី និងព័ត៌មានធីវីហ្វេសប៊ុក (TVFB News) ២០ករណី។



## ៣.២. ចំនួននិងស្ថានភាពករណីអំពើហិង្សាលើស្ត្រី

ពីខែមករាដល់ខែកញ្ញាឆ្នាំ២០១៩ តាមរយៈការរាយការណ៍តាមប្រភពព័ត៌មានខាងលើ មានករណីអំពើហិង្សាសរុបចំនួន ១៣៤ករណី ដែលត្រូវបានកត់ត្រា។ ក្នុងនោះ៥៩%ជាករណីអំពើហិង្សាលើស្ត្រី ៣៧%កើតលើកុមារ និង៤%កើតលើស្ត្រីនិងកុមារព្រមគ្នា។




ករណីរំលោភជាប្រភេទករណីដែលកើតឡើងញឹកញាប់ជាងគេរហូតដល់ទៅ ៥២% ក្នុងនោះ ៣%ជាករណីរំលោភបូក និង២%ជាករណីរំលោភសម្លាប់។ ករណីបន្ទាប់គឺប្រភេទអំពើហិង្សាលើរាងកាយក៏កើតឡើងញឹកញាប់ដែរ ២៥% និងករណីឃាតកម្ម ១៩% រីឯ៥%ទៀតជាករណីហិង្សាផ្នែកសេដ្ឋកិច្ច ហិង្សាផ្លូវចិត្ត និងការជួញដូរមនុស្ស។



ទីកន្លែងកើតហេតុភាគច្រើននៅភ្នំពេញ ៥១ករណី និងខេត្តកណ្ដាល ១៧ករណី។ សម្រាប់ខេត្តនានា មិនសូវមានការរាយការណ៍ករណីអំពើហិង្សាលើស្ត្រីទេ។ នេះមិនមែនមានន័យថានៅតាមខេត្តមិនសូវមានករណីអំពើហិង្សាលើស្ត្រីកើតឡើងនោះទេ អាចដោយសារអ្នកសារព័ត៌មានភាគច្រើននៅទីក្រុងភ្នំពេញ ហើយខ្វះអ្នកយកព័ត៌មាននៅតាមខេត្ត។

ផែនទីករណីអំពើហិង្សាលើស្ត្រីដែលបានរាយការណ៍




អំពើហិង្សាភាគច្រើនប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល ៤១% មិត្តភក្តិ អ្នកជិតខាង ឬអ្នកដែលស្គាល់គ្នា ១៨% ជាសាច់ញាតិ ជាពូ ជាឪពុកឬជាតា ១៥% អ្នករួមការងារ ជាប្រធានឬជាភ្ញៀវ ៥%។ មានតែ៩%ទេដែលជនមិនស្គាល់មុខ និង១២%ដែលយើងមិនដឹងពីទំនាក់ទំនងដោយសារមិនបានរាយការណ៍នៅក្នុងសារព័ត៌មាន។



តាមការរាយការណ៍ព័ត៌មានតាមប្រភពខាងលើ មានករណីភាគច្រើន ៧៧% ដែលជនមុខសញ្ញាត្រូវបានចាប់ខ្លួន។ ដោយឡែកយើងមិនដឹងថាជនមុខសញ្ញាត្រូវបានកាត់ទោសនិងទទួលទោសយ៉ាងណានោះទេដោយសារមិនសូវមានការរាយការណ៍ព័ត៌មានបន្ត។ ២៣%ទៀត សមត្ថកិច្ចកំពុងស្រាវជ្រាវចាប់ខ្លួនជនមុខសញ្ញា សម្រុះសម្រួលគ្នា ឬជនមុខសញ្ញាបានស្លាប់ ឬគ្មានការចាប់ខ្លួនដោយសារជាកុមារក្រោមអាយុ ១៨ឆ្នាំ ឬគ្មានព័ត៌មានបន្ត។




## ៣.៣. ការអនុវត្តតាមក្រមប្រតិបត្តិរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី

ក្រមប្រតិបត្តិរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី មានគោលបំណងផ្សព្វផ្សាយដល់អ្នកសារព័ត៌មានទាំងអស់ ឱ្យគោរពនូវគោលការណ៍វិជ្ជាជីវៈអ្នកសារព័ត៌មាន និងមានចំនុចមួយចំនួនដែលត្រូវធ្វើនិងមិនត្រូវធ្វើនៅពេលរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី ដើម្បីកុំឱ្យស្ត្រីជនរងគ្រោះនិងក្រុមគ្រួសារទទួលរងនូវផលប៉ះពាល់កាន់តែធ្ងន់ធ្ងរថែមទៀត បន្ថែមពីលើ ផលប៉ះពាល់ដែលពួកគាត់ទទួលរងពីអំពើហិង្សានោះ។ ក្រុមការងារបានបែងចែកប្រការដែលបានចែងនៅក្នុងក្រមប្រតិបត្តិជា៣ផ្នែកសំខាន់ៗរួមមាន៖ ការរាយការណ៍ព័ត៌មានដែលមិនគោរពសិទ្ធិឯកជនភាពនិងអត្តសញ្ញាណរបស់ជនរងគ្រោះ (ប្រការ ២, ៦, ៧) ការប្រើភាសាឬការវិនិច្ឆ័យដែលបន្ទោសជនរងគ្រោះ (ប្រការ១០, ១១, ១២) និងការរាយការណ៍ដែលមិនបង្ហាញពីគោលបំណងលើកកម្ពស់ការយល់ដឹងនិងលុបបំបាត់អំពើហិង្សាលើស្ត្រី និងថែមទាំងយកព័ត៌មាននេះមករាយការណ៍ជាការលេងសើច (ប្រការ៣, ៤, ៥, ១៣)។

ដើម្បីជាជំនួយដល់ក្រសួងទាំង២ក្នុងការធ្វើការជាមួយស្ថាប័នសារព័ត៌មានសំដៅកែលម្អការរាយការណ៍ព័ត៌មានរបស់ខ្លួនអំពីអំពើហិង្សាលើស្ត្រី ក្រុមការងារសម្រេចជ្រើសរើសយកស្ថាប័នព័ត៌មានចំនួនបួនដែលមានការរាយការណ៍ច្រើនជាងគេលើករណីហិង្សាលើស្ត្រី នោះគឺអរិយធម៌ (ដែលមាន២៨ករណី) KBN News (ដែលមាន២៣ករណី) កោះសន្តិភាព (ដែលមាន២៣ករណី) និង TVFB (ដែលមាន២០ករណី) ដើម្បីធ្វើការវិភាគលម្អិតលើការអនុវត្តក្រមប្រតិបត្តិរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី។ លទ្ធផលនៃការវិភាគឃើញថា ស្ថាប័ន ព័ត៌មានទាំងបួន មិនបានគោរពសិទ្ធិឯកជនភាពនិងអត្តសញ្ញាណ (៨៥% -១០០%) បន្ទោសជនរងគ្រោះឬយកលេសឱ្យជនប្រព្រឹត្ត (១៨% -៣៣%) យកការរាយការណ៍អំពើហិង្សាលើស្ត្រីជាការលេងសើច (៧% -៣៨%)។




## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ខណៈដែលរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី តាមរយៈការរាយការណ៍ព័ត៌មាននេះឃើញថាស្ថានភាពករណីអំពើហិង្សាលើស្ត្រី

និងកុមារនៅតែមានកម្រិតខ្ពស់គួរឱ្យបារម្ភ។ នេះទាមទារឱ្យមានការចូលរួមដោយយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។ តួយ៉ាង វិស័យសារព័ត៌មាន មានតួនាទីសំខាន់ណាស់ក្នុងការចូលរួមចំណែកលើកកម្ពស់ការយល់ដឹងនិងកែប្រែឥរិយាបថរបស់សាធារណជន ដើម្បីទប់ស្កាត់និងលុបបំបាត់អំពីហិង្សាលើស្ត្រី។ វាជាចំណុចវិជ្ជមានដែលមានស្ថាប័នសារព័ត៌មានជាច្រើនយកចិត្តទុកដាក់រាយការណ៍អំពីករណីអំពើហិង្សាលើស្ត្រី ក៏ប៉ុន្តែអ្វីដែលគួរធ្វើបន្ថែមគឺស្ថាប័នទាំងនោះគួរកែលម្អវិជ្ជាជីវៈរបស់ខ្លួនដោយគោរពឱ្យបាននូវក្រមប្រតិបត្តិរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី។

យោងតាមរបាយការណ៍នេះ អង្គការអាក់សិនអេតកម្ពុជា សូមលើកឡើងនូវអនុសាសន៍ជូនចំពោះស្ថាប័នសារព័ត៌មានទាំងបួន ដូចខាងក្រោម៖

១. បង្កើនការយល់ដឹងរបស់អ្នករាយការណ៍ព័ត៌មាន អ្នកអានព័ត៌មាន និងនិពន្ធនាយក អំពីឫសគល់នៃអំពើហិង្សាលើស្ត្រី។

២. បញ្ឈប់ការបង្ហាញនូវអត្តសញ្ញាណឬការបំពានលើសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ រួមមានការបង្ហាញនូវរូបភាពទាំងជនរងគ្រោះនិងជនមុខសញ្ញាទោះមានការបិទបាំងមុខខ្លះក៏ដោយ និងការបង្ហាញនូវរូបភាពអាក្រាតកាយ របួសធ្ងន់ធ្ងរឬសាកសពដែលធ្វើឱ្យអ្នកអានមានការតក់ស្លុតដែលនេះជាគោលការណ៍សំខាន់នៃក្រមវិជ្ជាជីវៈសារព័ត៌មាន។ ឈប់បង្ហាញនូវព័ត៌មានទាំងឡាយណាដែលអាចឱ្យគេកត់សំគាល់បាននូវអត្តសញ្ញាណរបស់ជនរងគ្រោះ។

៣. បញ្ឈប់ការស្តីបន្ទោសលើជនរងគ្រោះ ដែលថាមកពីនារីនោះស្រវឹង ស្លៀកខ្លីបញ្ចេញសាច់ យល់ព្រមទៅតាមការបបួលរបស់ជនប្រព្រឹត្ត ចេញដើរក្រៅពេលយប់ព្រលប់។

៤. បញ្ឈប់ការរកលេសឱ្យជនប្រព្រឹត្ត ដែលថាមកពីបុរសនោះស្រវឹង ប្រើគ្រឿងញៀន មានសតិមិនល្អ ប្រច័ណ្ឌ ឬទប់ចិត្តមិនបាន ដែលជាហេតុដែលបង្កឱ្យមានអំពើហិង្សាលើស្ត្រី។ ជនល្មើសត្រូវតែទទួលទោសដោយគ្មានការលើកលែង។

៥. បញ្ឈប់ការយកករណីអំពើហិង្សាមករាយការណ៍ជាលក្ខណៈលេងសើច ព្រោះបញ្ហាអំពើហិង្សាលើស្ត្រីនិងកុមារជាបញ្ហាធំរបស់ប្រទេសជាតិ ដែលរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលនៅកម្ពុជានិងទូទាំងសាកលលោកក្នុងធ្វើការប្រយុទ្ធប្រឆាំងដើម្បីទប់ស្កាត់និងលុបបំបាត់បញ្ហានេះ។ ការដែលយកករណីនេះមកលេងសើច វាបង្ហាញពីការធ្លាក់ចុះនៃក្រមសីលធម៌សង្គមនៅកម្ពុជា។

៦. អ្នកសារព័ត៌មានជាអ្នកមានចំណេះដឹងនិងវិជ្ជាជីវៈ ដូចនេះអ្នកសារព័ត៌មានមានតួនាទីលើកកម្ពស់ការយល់ដឹងនិងកែប្រែឥរិយាបថសង្គមឱ្យប្រសើរឡើង មិនគួរដើម្បីប្រជាប្រិយភាពបណ្ដោយឱ្យអ្នកអានអូសទាញខ្លួនឱ្យធ្វើខុសក្រមសីលធម៌វិជ្ជាជីវៈនោះទេ។

៧. នៅពេលរាយការណ៍ករណីអំពើហិង្សាលើស្ត្រី ត្រូវដកស្រង់មតិយោបល់ពីស្ថាប័នជំនាញពាក់ព័ន្ធ ឬអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យនេះ ដើម្បីឱ្យសាធារណជនបានយល់ថាបញ្ហាអំពើហិង្សាលើស្ត្រីមិនមែនជាបញ្ហាឯកជនដែលកើតលើអ្នកដទៃនោះទេ ផ្ទុយទៅវិញវាជាបញ្ហារួម ជាការទទួលខុសត្រូវរបស់សង្គមទាំងមូលក្នុងការរកយុត្តិធម៌ឱ្យជនរងគ្រោះ និងរកវិធានការទប់ស្កាត់និងលុបបំបាត់។

## ឧបសម្ព័ន្ធ៖ តារាងវិភាគព័ត៌មានរាយការណ៍ករណីអំពើហិង្សាលើស្ត្រី

| | ប្រភពពត៌មានអវិយធម៌ | ឈ្មោះអ្នកសរសេរអត្ថបទ | ចំណងជើង | សិទ្ធិឯកជនភាពនិងអត្តសញ្ញាណជនរងគ្រោះ | បន្ទោសជនរងគ្រោះ | យកករណីអំពើហិង្សាជាការលេងសើច |
|---|---|---|---|---|---|---|
| ១ | http://www.arey-news.com/archives/291829?fbclid=IwAR0iMyHtK8c0nJBrEs8J5Y-CTT-j9V8CWaxUqVGiUboe8Y4HjOYSS3XDFAI | មិនមានឈ្មោះ | ហៅក្មេងស្រីមកប្រាប់ថា "មានការចង់ប្រាប់" លុះឃើញឱកាសស្ងាត់ល្អ ចាប់រំលោភនាងវិញ នៅកំពង់ចាម | បង្ហាញរូបភាពជនរងគ្រោះ<br><br>ក្មេងស្រីរងគ្រោះ មានឈ្មោះគ.ធ … សព្វថ្ងៃស្នាក់នៅក្នុងមណ្ឌលកុមារកំព្រា ទីតាំងកើតហេតុខាងលើ។ | ចាប់រំលោភក្មេងស្រី សតិមិនប្រក្រតី<br><br>លុះឃើញឱកាសស្ងាត់ល្អ | មិនមានបញ្ហា |
| ២ | http://www.arey-news.com/archives/295201?fbclid=IwAR3mVr39XoAAP89SI4nZQ2UcDo1FyYq_fmemBRNUE00zC_MadkICPHJvYHk | មិនមានឈ្មោះ | ពូសាច់ថ្លៃម្នាក់ កម្លាំងនគរបាលចាប់ បន្ទាប់ពីជនសង្ស័យរូបនេះ បានធ្វើសកម្មភាពចាប់ចងក្មួយបំរុងរំលោភ ប៉ុន្តែជនរងគ្រោះស្រែកឲ្យគេជួយទាន់ នៅពោធិ៍សាត់ | ជនសង្ស័យជាប់ពាក់ព័ន្ធក្នុងករណីប៉ុនប៉ងរំលោភមិនបានសម្រេចឈ្មោះ ផន ពយ ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មានប្រពន្ធ និងកូនៗក្នុងបន្ទុកគ្រួសារ មានទីលំនៅ ស្ថិតក្នុងភូមិ.ឃុំកើតហេតុខាងលើ ហើយត្រូវជាឪពុកមាសាច់ថ្លៃ ជនរងគ្រោះផងដែរ ។ ជនរងគ្រោះឈ្មោះអាយុ ១៥ឆ្នាំ ។ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៣ | http://www.arey-news.com/archives/299006?fbclid=IwAR0rtpOW9tlXP9mrz5azY7ScEC3j-QTKxi3vVrTVgKkRMSp1VYNjCFRZYE4 | មិនមានឈ្មោះ | បុរសជាប្តីបានអារ.ក សម្លាប់ប្រពន្ធរបស់ខ្លួន ហើយរត់ទៅចង.កសម្លាប់ខ្លួន តាមក្រោយ ស្រ្តីរងគ្រោះដែលត្រូវប្តីអារកសម្លាប់ បម្រើការងារនៅធនាគារ ABA បន្សល់ទុកកូនស្រីអាយុ៣ឆ្នាំម្នាក់ នៅភ្នំពេញ | បង្ហាញសំបុត្រអាពាហ៍ពិពាហ៍ | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | http://www.arey-news.com/archives/309030?fbclid=IwAR2bjpbQ0wBa_ZETZNJXdvau2OYGexYYALNCMHVNhxw6UqyPpvjkTtv4-hQ | មិនមានឈ្មោះ | តាមចាប់កូនប្រុសមន្ត្រីជាន់ខ្ពស់ក្រសួងកិច្ចការនារី និងមានក្របខ័ណ្ឌជាមន្ត្រីយោធាទៀតផង ករណីការបាញ់ប្រហារនារីម្នាក់នៅក្នុងក្លឹប «លុច្យសារី» សមត្ថកិច្ចបានអះអាងទៀតថា ករណីផ្ទុះអាវុធ បណ្ដាលឲ្យរងរបួសផ្ដើមចេញពីការប្រចណ្ឌ | រូបភាពជនរងគ្រោះ<br><br>ជនរងគ្រោះឈ្មោះ នឹម លីណា ...ទីលំនៅផ្ទះលេខ៥៣ ផ្លូវ៣៣៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ | រកលេសឱ្យជនប្រព្រឹត្តៈ ផ្តើមចេញពីការប្រចណ្ឌ | មិនមានបញ្ហា |
| ៥ | http://www.arey-news.com/archives/320556?fbclid=IwAR0B5hS1G30EV-waVsQc_2VFvDSfDkqCJKsb7RfslkWJs44ZXivqX4OwdIQ | មិនមានឈ្មោះ | ឃាត់ខ្លួនយុវជនម្នាក់ ករណីចាប់រំលោភរហូតបានសម្រេចនៅភ្នំពេញ | បង្ហាញរូបជនរងគ្រោះ<br><br>ជនរងគ្រោះមានឈ្មោះ ស ណ ស រ | ករណីរំលោភមិនមែនជាការរួមភេទទេ បើទោះជាស្ត្រីជាសង្សារយលព្រមចេញក្រៅជាមួយហើយអង្គុយនិយាយគ្នាដល់កណ្ដាលអាធ្រាតក៏ដោយ៖ ជនសង្ស័យក៏បានអោបជនរងគ្រោះនិងរួមភេទរហូតបានសម្រេច | មិនមានបញ្ហា |
| ៦ | http://www.arey-news.com/archives/318237?fbclid=IwAR1ReMapvDqvjRPefHHLtbbXpE7mQj64TlfpZ3jvrM2_iAlYxAkvj18IDk4 | មិនមានឈ្មោះ | ហិង្សាក្នុងគ្រួសារ! ប្ដីខឹងប្រពន្ធមិនចូលផ្ទះ គំរាមដុត... នៅកណ្ដាល | ជនរងគ្រោះ ឈ្មោះ ណាន រឿន ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ស្នាក់នៅភូមិឃុំ-កើតហេតុ (ត្រូវជាប្រពន្ធ)។ ជនសង្ស័យ ឈ្មោះ ធឿន ធន ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ស្នាក់នៅភូមិ-ឃុំកើតហេតុ (ត្រូវជាប្តីឃាត់ខ្លួន)។ | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | http://www.arey-news.com/archives/319031?fbclid=IwAR0Uy5sEB7FYlvXTx3rhGZMqHeVNZOcgwNzlW_-z-TBCMy21-Y2AEefaEuY | មិនមានឈ្មោះ | ឃាត់ខ្លួនបុរសម្នាក់ ករណីប៉ុនប៉ងរំលោភសេពសន្ថវៈ នៅភ្នំពេញ | ជនសង្ស័យពាក់ព័ន្ធករណី ប៉ុនប៉ងរំលោភសេពសន្ថវៈ មានឈ្មោះ ផន ខន ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ អូសរទេះបន្លែ នៅចំណុចផ្ទះជួលលេខ ២៤DE2 ផ្លូវលេខ២៤៧ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ។<br><br>ជនសង្ស័យដែលជួលបន្ទប់ខាងលើផ្ទះជនរងគ្រោះស្នាក់នៅ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៨ | http://www.arey-news.com/archives/319066?fbclid=IwAR34X3RhKoFTXN-I3Y0hXutyAiGMvJRrx7WJr6-9gZK-CRq1YXELFBv_JIs | មិនមានឈ្មោះ | នារីស្រស់ស្អាតម្នាក់ ឈរចាំភ្ញៀវយកទៅដេក ក៏ត្រូវបានជនសង្ស័យ២នាក់ ជិះឡានមកកាប់ប្លន់ បានសម្រេច | បង្ហាញរូបភាពរបួសដែលគួរឱ្យរន្ធត់ | នារីស្រស់ស្អាតម្នាក់ ឈរចាំភ្ញៀវយកទៅដេក ក៏ត្រូវបានជនសង្ស័យ២នាក់ ជិះឡានមកកាប់ប្លន់ បានសម្រេច | ការរាយការណ៍លក្ខណៈលេងសើចៈ នារីស្រស់ស្អាតម្នាក់ ឈរចាំភ្ញៀវយកទៅដេក ក៏ត្រូវបានជនសង្ស័យ២នាក់ ជិះឡានមកកាប់ប្លន់ បានសម្រេច |
| ៩ | http://www.arey-news.com/archives/319591?fbclid=IwAR3hZOIdtODDUi6SQj2-r0-qSekIpocj-RjlPYr6EvUsIzriVO0xSaE-oLU | មិនមានឈ្មោះ | សាហាវមែន! ប្ដីចាក់សាំងដុតប្រពន្ធទាំងរស់ នៅកំពង់ចាម | ជនរងគ្រោះឈ្មោះ នួន អិត ភេទស្រី អាយុ ៤២ឆ្នាំ។ ជនសង្ស័យឈ្មោះ ចាន់ តឿ ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ<br><br>បង្ហាញរូបភាពជនរងគ្រោះស្ថិតក្នុងសភាពរបួសធ្ងន់ធ្ងរ | បង្ហាញថាស្រាជាលេសរបស់ជនប្រព្រឹត្តៈ ជារឿយៗគ្រួសារនេះ តែងឈ្លោះគ្នាមិនលុះថ្ងៃ ហើយនៅមុនពេលកើតហេតុ ប្ដីបាន ស្រវឹងស្រាប្រកែកគ្នា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១០ | http://www.arey-news.com/archives/320132?fbclid=IwAR2Ueqbewb4nhNUfZVLbXB8tUJGA8m7IxC6xF7oXGW4GC41Vcik1B-olt3E | មិនមានឈ្មោះ | ពូថ្លៃ ចាប់រំលោភ ក្មេងស្រី អាយុ ១២ឆ្នាំ នៅព្រៃវែង | ឈ្មោះ ព. គ ភេទស្រីអាយុ១២ ឆ្នាំ នៅខេត្តព្រៃវែង បានប្តឹង...ឈ្មោះ វ៉ាន់ ពៅភេទប្រុសអាយុ ៦០ឆ្នាំ នៅភូមិឃុំជាមួយគ្នា ( ត្រូវជាពូថ្លៃ )<br><br>រូបភាពជនមុខសញ្ញា និងរូបភាពជនរងគ្រោះព្រាលមុខ | មិនមានបញ្ហា | មិនមានបញ្ហា |
| ១១ | http://www.arey-news.com/archives/320733?fbclid=IwAR1g8UsPvpmlHNv8LzRUaL3RE8IjY5oiDjhdS1u26s2ZmbAjt3wcGIlvMgk | មិនមានឈ្មោះ | ក្មេងប្រុសម្នាក់ ពីបទចាប់រំលោភសេពសន្ថវៈ នៅព្រៃវែង | ទទួលពាក្យបណ្តឹងពីឈ្មោះ ជុន ថៅ ភេទស្រី អាយុ៥២ឆ្នាំ នៅភូមិ ថ្មី ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង ដែលបានមករាយការណ៍ និងប្តឹងទៅលើឈ្មោះ សារិទ្ធ កម្សត់ (ហៅ ធាន ) ភេទប្រុសអាយុ ១២ឆ្នាំ រស់នៅភូមិ ឃុំជាមួយគ្នា ( ពីបទចាប់រំលោភសេពសន្ថវៈ ) ទៅលើកូនស្រីរបស់គាត់ឈ្មោះ ស ឋ ន អាយុ ១៣ឆ្នាំ<br><br>រូបភាពទាំងជនរងគ្រោះនិងជនមុខសញ្ញា ព្រាលមុខ | មិនមានបញ្ហា | មិនមានបញ្ហា |
| ១២ | http://www.arey-news.com/archives/321552?fbclid=IwAR20zc0O8CtQYC_aOcw1wYyPxMP1_Ph0GN-eLOVIhzo5qOdrz-eI-MudHkg | មិនមានឈ្មោះ | ឳពុកចុងតិរិច្ឆាន! រហូតមានផ្ទៃពោះ២-៣ខែ ទើបបែកការរឿងឳពុកចុងរំលោភកូន នៅភ្នំពេញ | ឳពុកចុងឈ្មោះ បិច ឡា អាយុ ៣៩ ឆ្នាំ រស់នៅក្នុងភូមិឃុំជាមួយគ្នា<br><br>បង្ហាញរូបភាពជនមុខសញ្ញា ឯជនរងគ្រោះព្រាលមុខ | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣ | http://www.arey-news.com/archives/321620?fbclid=IwAR3sDUfudvRGtTN9GbyTOPEtJSBzmITTx2xuhg2ME6D2nKtvFo4_m5rqm8k | មិនមានឈ្មោះ | បុរសម្នាក់ ជាបុគ្គលិកលក់ផ្លែឈើ ធ្វើសកម្មភាពចាប់រំលោភនារីម្នាក់ជាចុងភៅ បានសម្រេចរហូតទៅដល់២ដង នៅភ្នំពេញ | នៅចំណុចក្រុមហ៊ុនលក់ផ្លែឈើមួយកន្លែង ផ្ទះលេខ៩២ ភូមិ៧ តាមបណ្តោយផ្លូវលេខ២៣០ ស្ថិតក្នុងសង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក។ ស្ត្រីរងគ្រោះឈ្មោះ វេង ស្រីលូត ភេទស្រី អាយុ ៣៤ឆ្នាំ មុខរបរចុងភៅស្នាក់នៅ ផ្ទះជួលភូមិ អូឌឹម សង្កាត់ចោមចៅ៣ខណ្ឌពោធិ៍សែនជ័យ<br>បង្ហាញរូបជនមុខសញ្ញា | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៤ | http://www.arey-news.com/archives/321703?fbclid=IwAR2f0o9oiioTdHVspWn7734XAMLJgYUsEuTxe75mSh6gw5FExAr2QXyuufU | មិនមានឈ្មោះ | នារីវ័យក្មេងម្នាក់រត់ទៅប្តឹងប៉ូលិស បន្ទាប់ពីបុរសជាគូសង្សារ បានប្រើអំពើហិង្សាជាញឹកញាប់ លើកចុងក្រោយវាយនាងប៉ោងភ្នែក | នារីរងគ្រោះឈ្មោះ សេង សម្ភស្ស អាយុ២៦ឆ្នាំ មុខរបរកម្មការនីរោងចក្រ ស្នាក់នៅបន្ទប់ជួលកន្លែងកើតហេតុបាន៤ថ្ងៃ ហើយមានទីលំនៅភូមិព្រៃក្រាយ សង្កាត់ស្នោខណ្ឌកំបូលរាជធានីភ្នំពេញ។<br><br>បង្ហាញរូបជនរងគ្រោះ | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៥ | http://www.arey-news.com/archives/321903?fbclid=IwAR02UX8P5wFNP60TECYucbJhlWZkyWU5USg3p2gRtJZ8ox5_J_YJ8dCbFR8 | មិនមានឈ្មោះ | ឃាត់ខ្លួនជនសង្ស័យម្នាក់ករណីរំលោភសេពសន្ថវៈក្មេងស្រី  ចាប់រំលោភរហូតបានសម្រេច នៅកំពង់ស្ពឺ | ជនសង្ស័យឈ្មោះ សួដាឡាត់ ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅក្នុងភូមិបេងឃុំស្ពុក ស្រុកគងពិសី។ ក្មេងស្រីរងគ្រោះមានឈ្មោះ ខ ស ល អាយុ១៧ឆ្នាំ រស់នៅក្នុងភូមិឃុំកើតហេតុខាងលើជាមួយគ្នា<br><br>បង្ហាញរូបជនសង្ស័យ | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | http://www.arey-news.com/archives/322019?fbclid=IwAR1NjyA0ecjzMKHbktFbpTGYdTVnL_ADZ5eKuTvaDooSVEjNwq-FwAu3U1I | មិនមានឈ្មោះ | ជនរូបនេះ និងប្តីរបស់នាង បានផឹកស្រាស្រវឹងជាមួយគ្នា រួចបានដេកនៅផ្ទះរបស់នាង ជននេះបានឆក់ឱកាសចាប់រំលោភនាង និងគំរាមនាងមិនឲ្យស្រែក នៅក្រចេះ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៧ | http://www.arey-news.com/archives/322127?fbclid=IwAR3-A1XmwR4uuf09CdsdbnvRq2kv4_Fhq1YvLO7QRfNMp6C2wNO-SAvUmjc | មិនមានឈ្មោះ | ឃាត់ខ្លួនបុរសម្នាក់ ពីបទរំលោភសេពសន្ថវៈលើកូនចុង នៅភ្នំពេញ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) ជនសង្ស័យត្រូវជាឪពុកចុងជនរងគ្រោះ | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៨ | http://www.arey-news.com/archives/323158?fbclid=IwAR1f1tAwY5nUk4RBwY5I9Qw2Tv_4i9FGq8XbROzSV7aApDoK-ApJEkbfCl0 | មិនមានឈ្មោះ | ឃាត់ខ្លួនជនសង្ស័យម្នាក់ លួងលោមចាប់បង្ខំរំលោភសេពសន្ធវៈ រហូតបានសម្រេចហើយបានបង្ខាំងខ្លួនទុកផ្ទះ ដើម្បីរំលោភទៀត នៅកំពត | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៩ | http://www.arey-news.com/archives/322877 | មិនមានឈ្មោះ | ប្តីស្រវឹងស្រាវាយប្រពន្ធ២ដៃ ចំក្តោងច្រមុះថប់ដង្ហើមប្រកាច់ស្លាប់ នៅភ្នំពេញ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ២០ | http://www.arey-news.com/archives/323553?fbclid=IwAR110WBfH_v9azLjfgXzeIVr4CBSaIBwfu9wBfc97p7f3OYMA5RFhTYyFJk | មិនមានឈ្មោះ | ថៅកែឡានដឹកខ្សាច់ វាយទៅលើស្ត្រីម្នាក់ បណ្ដាលឱ្យរបួសធ្ងន់ នៅសៀមរាប | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២១ | http://www.arey-news.com/archives/323466?fbclid=IwAR0mzXKevp-CFox2nTRZtzEUZe578xu1yj2uosOum8euXQDDKWfbXqq3x6E | មិនមានឈ្មោះ | ចាប់រំលោភបានសម្រេច ព្រឹកឡើងប្ដឹងនគរបាលចាប់ខ្លួន នៅភ្នំពេញ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២២ | http://www.arey-news.com/archives/323889?fbclid=IwAR0zxNODVTaGYsfXT7Y5i3TM0CNd-McE9uC_Kd-kIJeDzC2VFf3ddBkud4I | មិនមានឈ្មោះ | បុរសម្នាក់ ប្រើល្បិចល្បួងក្មេងស្រីយកទៅរំលោភ ប៉ុន្តែ មិនទាន់បាន ស៊ីជម្រៅ នៅឡើយទេ នៅបាត់ដំបង | បង្ហាញអត្តសញ្ញាណ ជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២៣ | http://www.arey-news.com/archives/324063?fbclid=IwAR2wG4AgvaPtDC33UJ7XO2w7NdVSdLCJVVjNv7MgQJ8pUpnDdi4mCUyIoRU | មិនមានឈ្មោះ | ឃាត់ចាប់ខ្លួនបុរសម្នាក់ តាមបណ្ដឹងស្ត្រីជាម្ដាយក្មេក ប្រើកណ្ដាប់ដៃដាល់កូនស្រីរបស់គាត់ នៅពោធិ៍សាត់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ២៤ | http://www.arey-news.com/archives/324318?fbclid=IwAR2EXnnlCqp2RoBMGzeK__wAhgxHHF2jyEN5cribK2Mgs_g8uXAR8X6QDzU | មិនមានឈ្មោះ | បុរសជនជាតិចិនម្នាក់ ពុំដឹងជាមានមូលហេតុអ្វី? ហៅជនជាតិចិន២នាក់ផ្សេងទៀត និងនារីជនជាតិខ្មែរ ជាអ្នកបកប្រែឲ្យខ្លួន ចូលមកក្នុងបន្ទប់ រួចចាក់សោរទាញកាំបិតប៉ុងតោ កាប់ទៅលើជនជាតិចិនគ្នាឯង បណ្ដាលឲ្យរងរបួសធ្ងន់ និងវាយធ្វើបាបនារីជាអ្នកបកប្រែម្នាក់ នៅកណ្ដាល | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២៥ | http://www.arey-news.com/archives/323749?fbclid=IwAR2uKapR0gKbICi27v2rb0Rg2AEf802F2dL0N0lwvkCShQ0QT3ecvwDZRIw | មិនមានឈ្មោះ | ឃាតកម្ម ! ប្ដី ចិត្តតិរិច្ឆាន យកពូថៅវាយ និងយកកាំបិតអារ-ក ស្លាប់យ៉ាងអាណោចអធម នៅតាកែវ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព)<br>បង្ហាញរូបភាពជនរងគ្រោះក្នុងស្ថានភាពរបួសស្លាប់និងមានឈាមជោគជាំ | មិនមានបញ្ហា | មិនមានបញ្ហា |
| ២៦ | http://www.arey-news.com/archives/324127?fbclid=IwAR3JlIYXGU6zeTHzyrXh2oGcBP4NI0GZPVufX4Trj9XyEpEUuZdFC9UzsdM | មិនមានឈ្មោះ | ឃាត់ខ្លួនបុរសម្នាក់ ករណីរំលោភសេពសន្ថវៈ នៅស្វាយរៀង | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | រៀបរាប់លម្អិតពីសកម្មភាពរំលោភដែលមិនចាំបាច់ដាក់បញ្ចូលក្នុងព័ត៌មាន ប៉ះពាល់អារម្មណ៍អ្នកអាន និងកិត្តិយសជនរងគ្រោះយ៉ាងខ្លាំង |

| | | | | | | |
|---|---|---|---|---|---|---|
| ២៧ | http://www.arey-news.com/archives/326188?fbclid=IwAR3CeS1_c5fM7-jKxyUipdbyRkw8q9Os8kO2gi3U-VeDVV67_vBOeSrS-WA | មិនមានឈ្មោះ | បុរសម្នាក់ ចាប់រំលោភក្មេងស្រី អាយុ១២ឆ្នាំម្នាក់ បានសម្រេច នៅក្រចេះ | បង្ហាញបង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២៨ | http://www.arey-news.com/archives/327216?fbclid=IwAR2lqEWcSyG95nsNj-3XO-D68oLNs1T6hqM0JeeOjzs213FG47CvO7IOx6w | មិនមានឈ្មោះ | ឃាត់ខ្លួនបុរសម្នាក់ ប្រទូស្តកេរ៍កេរ្តិ៍ ក្មេងស្រីអាយុ ៤ឆ្នាំ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | ប្រភពព័ត៌មាន KBN News | ឈ្មោះអ្នកសរសេរអត្ថបទ | ចំណងជើង | សិទ្ធិឯកជនភាពនិងអត្តសញ្ញាណជនរងគ្រោះ | បន្ទោសជនរងគ្រោះ | យកករណីអំពើហិង្សាជាការលេងសើច |
|---|---|---|---|---|---|---|
| ១ | https://kbn.news/archives/121252 | មិនមានឈ្មោះ | សមត្ថកិច្ចឃាត់ខ្លួនបុរសម្នាក់ស្រវឹងស្រា បង្កហិង្សាលើស្ត្រីម្នាក់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកការស្រវឹងជាលេសនៃអំពើហិង្សា | មិនមានបញ្ហា |
| ២ | https://kbn.news/archives/124703 | មិនមានឈ្មោះ | ព្រះអើយ សម្បូរពួកអាវិលោភក្មេងម្ល៉េះ! ក្មេងស្រី៤ឆ្នាំ ជនល្មោភកាមចាប់រំលោភ សំណាងបានជីដូនជួយទាន់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះជនមុខសញ្ញា និងឈ្មោះជីដូនជនរងគ្រោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៣ | https://kbn.news/archives/124710 | មិនមានឈ្មោះ | ព្រះអើយ ! អស់ពីចាប់រំលោភក្មេងស្រី ចូលដល់ចាប់រំលោភយាយ៧៨ឆ្នាំ | បង្ហាញទីតាំងកើតហេតុដែលជាផ្ទះជនរងគ្រោះ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៤ | https://kbn.news/archives/126148 | មិនមានឈ្មោះ | ចង់ជានាជាមួយប្រពន្ធ ខឹងនាងដេរស្តី វាយសន្លប់ស្តូក | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៥ | https://kbn.news/archives/125722?fbclid=IwAR3i0g23anHKguh_AN4I2g2P9TLAbnc1hYTieANIOfNcnI5tnUVSqI9ytFw | មិនមានឈ្មោះ | មន្ត្រីនគរបាល១ក្រុម និងបក្សពួក បង្ខំឲ្យនារីកាប៉ាអូខេផឹកថ្នាំម្យ៉ាង ស្លាប់១ របួស៣នាក់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៦ | https://kbn.news/archives/125890 | មិនមានឈ្មោះ | ស្រីអន់ចរឹត! ឲ្យនៅផ្ទះគិតតែដើរផឹក ប្តីមកទាន់វាយទាត់ធាក់ដុះក្អែលចេញម្តង | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (រូបភាព) | ស្រីអន់ចរឹត! ឲ្យនៅផ្ទះគិតតែដើរផឹក ប្តីមកទាន់វាយទាត់ធាក់ដុះក្អែលចេញម្តង | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | https://kbn.news/archives/126794 | មិនមានឈ្មោះ | ចូលចាប់រំលោភកូនស្រីគេ ដល់ក្នុងបន្ទប់ ព្រឹកឡើងខ្មោះ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ) ទីតាំងកើតហេតុដែលជាផ្ទះជនរងគ្រោះ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៨ | https://kbn.news/archives/126804 | មិនមានឈ្មោះ | ខឹងប្រពន្ធទិញបន្លែមិនល្អមកធ្វើម្ហូប ប្ដីកំណាចចាប់ជើងកូនតូចបោកនឹងសសរផ្ទះស្លាប់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) បង្ហាញរូបភាពលម្អិតពីទិដ្ឋភាពនៃការស្លាប់ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៩ | https://kbn.news/archives/126894 | មិនមានឈ្មោះ | សាហាវមែន! ចាប់ស្រីស្នេហ៍ដាក់ច្រវាក់ រួចយកខ្សែភ្លើងវាយធ្វើទារុណកម្មដូចសត្វធាតុ សង្ស័យនាងលួយលុយនិងទូរស័ព្ទ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១០ | https://kbn.news/archives/127429 | មិនមានឈ្មោះ | ស្រវឹងស្រាចូលចិត្តវាយដំប្រពន្ធកូន រួចឆ្លើយថា អត់ដឹងអីផង ម្ដងនេះខ្មោះ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកការស្រវឹងជាលេសនៃអំពើហិង្សា | មិនមានបញ្ហា |
| ១១ | https://kbn.news/archives/127771 | មិនមានឈ្មោះ | ស្វាវឡើងកចាប់កូនក្រមុំគេឱបថើបទាំងថ្ងៃ ចុងក្រោយជាប់ខ្នោះ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | ស្វាវឡើងកចាប់កូនក្រមុំគេឱបថើបទាំងថ្ងៃ ចុងក្រោយជាប់ខ្នោះ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | https://kbn.news/archives/127629 | មិនមានឈ្មោះ | ប្តីជាន់កប្រពន្ធរើបម្រះរួចខាំដៃវិញ ប្តីឈឺទាញដៃ ស្រាប់តែប្រពន្ធបាក់ធ្មេញមុខអស់២ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | កណ្ដុំផែប! ប្តីជាន់កប្រពន្ធយកដីញាត់មាត់ ប្រពន្ធរើបម្រះរួចខាំដៃវិញ ប្តីឈឺទាញដៃ ស្រាប់តែប្រពន្ធបាក់ធ្មេញមុខអស់២ |
| ១៣ | https://kbn.news/archives/128531 | មិនមានឈ្មោះ | ព្រះអើយ! ជនល្មោភកាមពនាក់ ចាប់ចងដៃចងជើង និងបញ្ចូកថ្នាំងងុយដេកក្មេងស្រីអាយុ១១ឆ្នាំ ដើម្បីរំលោភ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ (ឈ្មោះ)<br>ប្រាប់ឈ្មោះម្តាយជនរងគ្រោះ ប្រាប់ឈ្មោះសាក្សី | មិនមានបញ្ហា | ផ្តល់ពត៌មានលម្អិតពេកពីការកើតហេតុ |
| ១៤ | https://kbn.news/archives/128582 | មិនមានឈ្មោះ | គោចាស់ចង់ស៊ីស្មៅខ្ចី! ត្រូវសមត្ថកិច្ចឃាត់ ក្រោយចាប់ក្មេងស្រីរំលោភរួចគេចខ្លួន១២ឆ្នាំ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព)<br><br>ទីតាំងកើតហេតុ | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៥ | https://kbn.news/archives/129265 | មិនមានឈ្មោះ | ក្រោយៗឲ្យរាង! បុរសរត់ម៉ូតូកង់បីស្រវឹងស្រាវាយ ស្រីខាវ៉ាអូខេសន្លប់ស្តូកស្តឹង ពលរដ្ឋផ្ទុះកំហឹងស្វាគមន៍សងវិញ ហូរឈាមស្រោចខ្លួន | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព)<br>បង្ហាញរូបភាពលម្អិតនៃទិដ្ឋភាពរបួសមានឈាម | យកការស្រវឹងជាលេសនៃអំពើហិង្សា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦ | https://kbn.news/archives/131344 | មិនមានឈ្មោះ | អាសូរនាងណាស់! ម៉ែឪទៅធ្វើការនៅថៃ កូនស្រី១៣ឆ្នាំ កញ្ជាស់៦៤ឆ្នាំ ចាប់រំលោភ៣លើក | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៧ | https://kbn.news/archives/131401 | មិនមានឈ្មោះ | ក្មេងប្រុសអាយុ១៤ឆ្នាំល្បួងក្មេងស្រីអាយុ១០ឆ្នាំ រំលោភសេពសន្ថវៈ ឪពុកក្មេងស្រីមកទាន់បែកការណ៍ប្ដឹងសមត្ថកិច្ចឲ្យចាប់ខ្លួន | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព)<br><br>ទីតាំងកើតហេតុ ជនរងគ្រោះ និងជនសង្ស័យរស់នៅផ្ទះជាមួយគ្នា | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៨ | https://kbn.news/archives/131969 | មិនមានឈ្មោះ | ល្បួងម៉ាប់ស្រវឹងស្រាកម្រើកសរសៃ! ចូលចាប់រំលោភកូនក្រមុំគេក្នុងមុខ នាងស្រែកហៅឪម៉ែជួយ ផ្អើលភូមិ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកការស្រវឹងជាលេសនៃការរំលោភ | ល្បួងម៉ាប់ស្រវឹងស្រាកម្រើកសរសៃ! ចូលចាប់រំលោភកូនក្រមុំគេក្នុងមុង នាងស្រែកហៅឪម៉ែជួយ ផ្អើលភូមិ |
| ១៩ | https://kbn.news/archives/132601 | មិនមានឈ្មោះ | ម្យ៉ាងម្នាក់! ប្រពន្ធញៀនល្បែងប្ដីញៀនស្រា! ខឹងប្រពន្ធនៅផ្ទះគេ ប្ដីកើតចិត្តដុតផ្ទះចោលហ្មត់.. | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | ម្យ៉ាងម្នាក់! ប្រពន្ធញៀនល្បែងប្ដីញៀនស្រា! ខឹងប្រពន្ធនៅផ្ទះគេ ប្ដីកើតចិត្តដុតផ្ទះចោលហ្មត់ | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ២០ | https://kbn.news/archives/132595 | មិនមានឈ្មោះ | នាំមិត្តស្រីមកលេងបន្ទប់ជួល ឃើញនាងដេកលើគ្រែដូច ទំនង ក៏រំលោភតែម្តងទៅ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | ឃើញនាងដេកលើគ្រែដូចទំនង ក៏រំលោភតែម្តងទៅ | ឃើញនាងដេកលើគ្រែដូច ទំនង ក៏រំលោភតែម្តងទៅ |
| ២១ | https://kbn.news/archives/132651?fbclid=IwAR0V1WBxt7NAqE5AnD_nQsbhL05R94DpmLZ2ua-g3vepGbMvcRm6WZUjtP8 | មិនមានឈ្មោះ | មេម៉ាយ២ភ្លើង! ជួបប្តីទី៣ប៉ះ ប្រុសប្រមឹក... ខ្លាំងរឿងម្យ៉ាង រហូតនាងទប់លែងជាប់ រត់រក ប៉ូលីសជួយ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និង ជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មេម៉ាយ២ភ្លើង! ជួបប្តីទី៣ ប៉ះប្រុសប្រមឹក... |
| ២២ | https://kbn.news/archives/133044 | មិនមានឈ្មោះ | សាហាវណាស់! ប្តីញៀនថ្នាំ ចាប់អូសប្រពន្ធ យកទៅអារ .ក សម្លាប់ចោល... | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកហេតុផលនៃការញៀនថ្នាំជា លេសនៃអំពើហិង្សា | មិនមានបញ្ហា |
| ២៣ | https://kbn.news/archives/132932 | មិនមានឈ្មោះ | អាសូរនាងណាស់! ទើបអាយុ ៩ឆ្នាំសោះ ត្រូវឪពុកចុង តិរច្ឆានចាប់រំលោភ... ធ្លាក់ ឈាមទាំងថ្លុក... | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា និងជនរងគ្រោះ (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | ប្រភពព័ត៌មានកោះសន្តិភាព | ឈ្មោះអ្នកសរសេរអត្ថបទ | ចំណងជើង | សិទ្ធិឯកជនភាពនិងអត្តសញ្ញាណជនរងគ្រោះ | បន្ទោសជនរងគ្រោះ | យកករណីអំពើហិង្សាជាការលេងសើច |
|---|---|---|---|---|---|---|
| ១ | https://kohsantepheapdaily.com.kh/article/817742.html | ចុកសុខា | យកកាំភ្លើងច្នៃបាញ់ប្រពន្ធ...ក្រោយទាស់សម្ដីពេលស្រវឹង | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកភាពស្រវឹងជាលេសនៃអំពើហិង្សា | មិនមានបញ្ហា |
| ២ | https://kohsantepheapdaily.com.kh/article/830240.html?fbclid=IwAR2K-K_R3luHVdKP-MOFd0iu546O_zzhRy0zfcbUuTus30NwhN2RM8rVJqo | យន់ស៊ីថា | សម្ដីនរកកូនប្រុស៖«បើម៉ែឯងមិនព្រម យប់នេះ ខ្ញុំនឹងសម្លាប់ចោលហើយ» | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៣ | https://news.kohsantepheapdaily.com.kh/article/736848.html?fbclid=IwAR0Sp05kz8VV3GOFunUQb0qp_E-RW4euLENhpU8z-FGUF5Qm-8jnP3f1Y3s | សែមមុនីជាតិ | លួចមើលនារីបត់ជើង ផ្ទុះអារម្មណ៍ស្ទុះទៅចាប់រំលោភតែមិនសម្រេច | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | លួចមើលនារីបត់ជើង ផ្ទុះអារម្មណ៍ស្ទុះទៅចាប់រំលោភ | លួចមើលនារីបត់ជើង ផ្ទុះអារម្មណ៍ស្ទុះទៅចាប់រំលោភ |
| ៤ | https://kohsantepheapdaily.com.kh/article/854818.html?fbclid=IwAR11uA-iQwgz_Jg62C2NJXRsAMTibqYfV-vPgCgUtujAq0pEXEnJKAV7BmE | យឹមឈឿន | ត្រឹមមួយដៃ ស្រីស្នេហ៍សន្លប់ស្តូកស្តឹង | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | ត្រឹមមួយដៃ ស្រីស្នេហ៍សន្លប់ស្តូកស្តឹង |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | https://kohsantepheapdaily.com.kh/article/855585.html?fbclid=IwAR3mS1Il2KlhhC_q9TerANA8sQMt1lUpwOcaBrMMLyNByPAHu9HRcwK6oYs | យន់ស៊ីថា | ហួសថ្លៃង! ឪពុកម្តាយរវល់ខួបកំណើតក្បែរផ្ទះ ស្រាប់តែកូនស្រីតូចត្រូវគេធ្វើអីៗយ៉ាងឈឺផ្សា | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | បន្ទោសឪពុកម្តាយជនរងគ្រោះមិនបានមើលកូន | ហួសថ្លៃង! ឪពុកម្តាយរវល់ខួបកំណើតក្បែរផ្ទះ ស្រាប់តែកូនស្រីតូចត្រូវគេធ្វើអីៗយ៉ាងឈឺផ្សា |
| ៦ | https://news.kohsantepheapdaily.com.kh/article/737002.html?fbclid=IwAR0Y_wme4DFKFQ7XrYoMIAfSoJDFblV7Xm7JOLYULYMUKFZhko8VROg4ldU | សែមមុនីជាតិ | មុននឹងរំលោភប្រើម្រាមដៃសិន មានអីត្រូវនាងស្រែកផ្អើលអ្នកភូមិ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មុននឹងរំលោភប្រើម្រាមដៃសិន មានអីត្រូវនាងស្រែកផ្អើលអ្នកភូមិ |
| ៧ | https://kohsantepheapdaily.com.kh/article/861698.html?fbclid=IwAR23CfscysDLEFsjPpEOI18sRNjeLeX5Nj0iMJ3JETF4s6sFYojf0VQv714 | បុនលីនណា | កូនគេ កូនយើង...សម្រេច៥ដងមកហើយដែលលោកតានេះធ្វើដាក់នាងតូចម្នាក់នេះ! | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៨ | https://news.kohsantepheapdaily.com.kh/article/737134.html | សែមមុនីសុជាតិ | អោយតែស្រាចូលខ្លួនដឹងតែវាយទាត់ធាក់ តើប្រពន្ធណាទ្រាំបាន | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | យកស្រាជាលេសនៃអំពើហិង្សា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | https://kohsantepheapdaily.com.kh/article/865600.html?fbclid=IwAR1ofooRuI2V6fg3gKxeemx3BSxJV_7paXCN6pG8CaD7_pk_9ABReRMIwjU | ស្រីណា | ដេញកាប់ប្រពន្ធស្លាប់លើចិញ្ចើមផ្លូវ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១០ | https://kohsantepheapdaily.com.kh/article/867648.html?fbclid=IwAR0lzmDlhUvnUMwxDRaxDWqKOcIN0NdlIVhShseBbyDS9qmli801pO72PPc | ណុបរក្សា | សៀតពូថៅនឹងចង្កេះតាមរកប្រពន្ធដល់ផ្ទះម៉ែក្មេកទៀត ចុងក្រោយប្រពន្ធទ្រាំលែងបាន... | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១១ | https://kohsantepheapdaily.com.kh/article/871230.html?fbclid=IwAR121_clKuq2wCl5GaVhU0k8vlbcS5hdFSPLufiA2itTwzducQZnqtP41pw | ប៊ុនលីនណា | ហួសថ្លៃង! ឧបសង្សារចូលព្រៃស្ងាត់ រួចចាប់នាងម្តងម្នាក់ៗ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១២ | https://kohsantepheapdaily.com.kh/article/870867.html?fbclid=IwAR1mKzyHpF9Cx99K4UY_YBuaV25cr7gndF8LSatGwO0kiJuc50SHC10MSNw | យឹមឈឿន | ប្រពន្ធពឹងបន្តិច ប្តីថា «រំខាន អើយរំខាន រកតែ...» ស្រាប់តែផ្ទុងហូរឈាមកក្លាក់ផ្អើលឆោឡោ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | រីឯលោកប្តីវិញប្រើកណ្តាប់ដៃវាយផ្ទុងបែកថ្ងាសហូរឈាមកក្លាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣ | https://kohsantepheapdaily.com.kh/article/872178.html?fbclid=IwAR3SLbGNcWIp9Nt4nEMIdRVuqF2FrA3DkCNF7IOPfGJe_3dLZ3VADOQccsg | យឺមប៊ុនណាក់ | ម្តាយក្មេកចោទថាបើកមុងចូលអីអី ខណៈដេកជាមួយចៅស្រី តែកូនប្រសារ... | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ) | មិនមានបញ្ហា | ម្តាយក្មេកចោទថាបើកមុងចូលអីអី |
| ១៤ | https://kohsantepheapdaily.com.kh/article/876118.html?fbclid=IwAR2nQxsysRAi97XcPFpKhNCJL1_MBJ_0bsOa4nHfsO4OrR8K0xjX2zL83a8 | ម៉េងជា | ដឹងមូលហេតុខ្លះៗហើយ លើករណីសង្ស័យរំលោភ រួចសម្លាប់ចោលបំបាត់ភស្តុតាង | មិនមានបញ្ហា | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៥ | https://kohsantepheapdaily.com.kh/article/876165.html?fbclid=IwAR0Ae61oABciCVgWkNFW88m0erifRXPt3TrZCcNovoknb3_zBDVGCn6hHOw | យឹមប៊ុនណា | នាងថា «ចូលទៅចាប់ផ្តួលក្នុងបន្ទប់ទឹក គ្មាននិយាយគ្នាប្រាប់មុនមួយម៉ាត់ ទើបនាង... » | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | រាយការណ៍មិនច្បាស់លាស់ធ្វើឲ្យគេយល់ច្រលំលើជនរងគ្រោះ | នាងថា «ចូលទៅចាប់ផ្តួលក្នុងបន្ទប់ទឹក គ្មាននិយាយគ្នាប្រាប់មុនមួយម៉ាត់ ទើបនាង... » |
| ១៦ | https://kohsantepheapdaily.com.kh/article/881038.html?fbclid=IwAR00sZk-N65FyTv0wiN51Ai7tm4kUkuLYUsttVUYb3Y-3J31uQzf3mFlfjc | ចាន់ស្មើ | ចាក់សោផ្ទះ និងចាក់សាំងដុតផ្ទះស្លាប់ប្រពន្ធ និងកូនយ៉ាងវេទនា | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | https://kohsantepheapdaily.com.kh/article/882215.html?fbclid=IwAR1GSoW3g3V6-Hu-4AkNLEx1-v1QEboNIzbN7L83RA23Ec8mVXixCKrCckQ | យឹមឈឿន | សុំលុយប្រពន្ធថា«អត់» ប្ដីថា «ខំរកលុយឱ្យរាល់ថ្ងៃនៅតែអត់ទៀត ឬលួចមាន...» ផ្អើល | មិនមានបញ្ហា | ចំណងជើងដាក់កំហុសទៅលើជនរងគ្រោះ | មិនមានបញ្ហា |
| ១៨ | https://kohsantepheapdaily.com.kh/article/901920.html?fbclid=IwAR0vaHIv3HY3wm0Hnq4bdVa86Z6g0JM0do0gkspWX-hejLqc2KlH8CR7K3U | យន់ស៊ីថា | ណាត់គ្នាតាមឆាតហ្វេសប៊ុករួចទៅសុំបន្ទប់បងធម៌... បានសម្រេច២ដងបែកធ្លាយ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៩ | https://kohsantepheapdaily.com.kh/article/902418.html | យន់ស៊ីថា | ឃើញឈ្លោះជាមួយសង្សារពេក ខំហៅមកដេក...តណ្ហា២ដង១យប់ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | លុះយប់ជ្រៅយុវជននោះមានចំណង់ផ្លូវភេទក៏បានបង្ខំនាងម្នាក់នោះរួមភេទរហូតបានសម្រេចជាបន្តបន្ទាប់ គួរបែងចែករវាងពាក្យថារួមភេទនិងករណីរំលោភ | ឃើញឈ្លោះជាមួយសង្សារពេក ខំហៅមកដេក...តណ្ហា២ដង១យប់ |
| ២០ | https://kohsantepheapdaily.com.kh/article/909107.html | ឆោមពិសម័យ | គ្រាន់ប្អូនស្រីមិនបានឱ្យបាយហូប១ថ្ងៃ ចាប់នាងអារ.កលើប៉ៅអី | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២១ | https://kohsantepheapdaily.com.kh/article/917987.html?fbclid=IwAR27LX6hLHAZVjgCXG6TMF-UomSJFzivDn5K95KCINann_R29r2SdpfSiqE | យឹមបុនណាក់ | ថ្ងៃជិតអស្ដង្គតទៅហើយ ឃើញនាងអង្គុយកាត់ស្មៅ បែកគំនិតទ្រាំលែងបាន | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |

| | ប្រភពព័ត៌មាន TVFB News | ឈ្មោះអ្នកសរសេរអត្ថបទ | ចំណងជើង | សិទ្ធិឯកជនភាពនិងអត្តសញ្ញាណជនរងគ្រោះ | បន្ទោសជនរងគ្រោះ | យកករណីអំពើហិង្សាជាការលេងសើច |
|---|---|---|---|---|---|---|
| ១ | https://tvfbonline.com/article?id=11898 | មិនមានឈ្មោះ | ឪពុកចុងចិត្តអប្រិយ លួងលោមកូនស្រីអាយុ១៣ឆ្នាំ យកទៅរំលោភក្នុងផ្ទះសំណាក់ដាលីន បានសម្រេច៣ដង | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២ | https://tvfb.news/article/20147?fbclid=IwAR3iL-UpOAwrh46Yzr6Yj3S6mrLDt7Ohy3xoIAClC4sY-YHxI2ixkshJxaM | មិនមានឈ្មោះ | សកម្មភាពហិង្សា របស់បុរស វ័យចំណាស់ម្នាក់បាន លើកដៃ ទះប្អូនស្រី មួយដៃចំកណ្តាលមុខ | មិនមានបញ្ហា | មិនមានបញ្ហា | មិនមានបញ្ហា |
| ៣ | https://tvfbonline.com/article?id=12225 | មិនមានឈ្មោះ | បុរសម្នាក់ រួមភេទជាមួយអនីតិជន អាយុទើប១៤ឆ្នាំ ព្រះរាជអាជ្ញាខេត្តកណ្តាលបញ្ជាឱ្យឃាត់ខ្លួន | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៤ | https://tvfbonline.com/article?id=12472&fbclid=IwAR3Qgr3HPhjTydicZScX543Fk5wqp-fnEAB_Dz3QBX5ac2eSnV_PyYz4WkM | មិនមានឈ្មោះ | បងប្រុសតណ្ហាក្រាស់ម្នាក់ ក្រោយចាប់រំលោភប្អូនស្រីបង្កើត២នាក់ជាច្រើនលើក និងអស់រយៈពេលជាច្រើនឆ្នាំ ទើបតែបែកការ! | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៥ | https://tvfbonline.com/article?id=12258 | មិនមានឈ្មោះ | បុរសម្នាក់ទាញពូថៅកាប់សម្លាប់ប្រពន្ធ និងកូនប្រុសបង្កើតអាយុ៩ឆ្នាំ រងរបួសធ្ងន់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) បង្ហាញរូបភាពលម្អិតនៃទិដ្ឋភាពនៃការស្លាប់ | មិនមានបញ្ហា | មិនមានបញ្ហា |
| ៦ | https://tvfbonline.com/article?id=12402&fbclid=IwAR2Zdtf-2ASkO7P_0NBJP72kbNyrx0xWUdxe4KSqDKe6QULjXyZ64vJ0eJo | មិនមានឈ្មោះ | ឪពុកចុងចាក់សម្លាប់កូនអាយុ៦ឆ្នាំ និងប្រពន្ធរបួសធ្ងន់ធ្ងរ នៅខេត្តព្រះសីហនុ!!! | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | https://tvfbonline.com/article?id=12422 | មិនមានឈ្មោះ | ជនជាតិវៀតណាមម្នាក់ ចាប់រំលោភសេពសន្ថវៈទៅលើក្មេងស្រីអាយុ៨ឆ្នាំ | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ៨ | https://tvfbonline.com/article?id=12507 | មិនមានឈ្មោះ | បុរសម្នាក់ តណ្ហាឡើងខ្លាំង យកកាំបិតភ្ជង់រំលោភដល់លើផ្ទះ រហូតបានសម្រេចត្រូវសមត្ថកិច្ចចាប់វាយខ្នោះ | បង្ហាញអត្តសញ្ញាណជនជនមុខសញ្ញា (រូបភាព) | មិនមានបញ្ហា | ជនរងគ្រោះ ក៏បានចូលមកដេក ...ដោយសម្លៀកបំពាក់រ៉ូប ពណ៌ផ្កាឈូកគ្មានលីអូទេ |
| ៩ | https://tvfbonline.com/article?id=12823&fbclid=IwAR1yNqGVAlnTfUouN5ECcjADDgVcc3jfPvM80H3mAWVOIVuIhqHEaoGyzkk | មិនមានឈ្មោះ | យុវជន២នាក់ ចាប់រំលោភបូកលើនារីម្នាក់ពេលនាងស្រវឹង.. | បង្ហាញអត្តសញ្ញាណជនជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១០ | https://tvfbonline.com/article?id=12834&fbclid=IwAR14EjlM2BXJaUV-L2isxFrPp21J_F2B2mJuQKYRhkxnrr6rszRVzoINXtk | មិនមានឈ្មោះ | ប្រច័ណ្ឌប្រពន្ធ ចោទថាប្រពន្ធមានសាហាយស្មន់ ប្តីទាញពូថៅ កាប់.កប្រពន្ធ២ពូថៅស្លាប់មួយរំពេច រួចរត់ទៅប្រាប់អ្នកភូមិថា អញកាប់ប្រពន្ធអញងាប់ហើយ!!! | បង្ហាញឈ្មោះជនរងគ្រោះ រូបជនមុខសញ្ញា | រំលេចយកការប្រច័ណ្ឌជាហេតុផលនៃការសម្លាប់ប្រពន្ធ | មិនមានបញ្ហា |
| ១១ | https://tvfbonline.com/article?id=12910&fbclid=IwAR0zbC0rnvitTDoRSvCaRoE3he85VcuWvlsrnUaydo5zSjhpcGZJbPapg1w | មិនមានឈ្មោះ | នាំស្រីស្នេហ៍មកដេកផ្ទះសំណាក់រំចង់ រួចរឹត.កសម្លាប់បំបិទមាត់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ (រូបថត ឈ្មោះ) | មិនមានបញ្ហា | នាំស្រីស្នេហ៍មកដេកផ្ទះសំណាក់រំចង់ រួចរឹត.កសម្លាប់បំបិទមាត់ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | https://tvfb.news/article/22036 | មិនមានឈ្មោះ | ហួសចិត្ត! កំពុងតែដេកជិតប្រពន្ធសុខៗ ស្រាប់តែបើកភ្នែកឡើង ឃើញមិត្តភក្តិនៅពីលើប្រពន្ធ | មិនមានបញ្ហា | មិនមានបញ្ហា | ហួសចិត្ត! កំពុងតែដេកជិតប្រពន្ធសុខៗ ស្រាប់តែបើកភ្នែកឡើង ឃើញមិត្តភក្តិនៅពីលើប្រពន្ធ |
| ១៣ | https://tvfbonline.com/article?id=13814 | មិនមានឈ្មោះ | ប្តីសតិមិនល្អ ចាក់សាំងដុតអីវ៉ាន់ ចាប់ហួយក្នុងផ្ទះឆេះទាំងប្រពន្ធកំពុងដេកក្នុងមុង ស្លាប់ក្រោយបញ្ជូនទៅពេទ្យបាន ១ថ្ងៃ ចំណែកប្តីអារ.កខ្លួនឯងតាមក្រោយ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ និងរូបថត) | យកហេតុផលសតិមិនល្អជាលេសនៃការដុតផ្ទះសម្លាប់ប្រពន្ធ | មិនមានបញ្ហា |
| ១៤ | https://tvfbonline.com/article?id=13961 | មិនមានឈ្មោះ | ២នាក់បងប្អូន ត្រូវកូនអ្នកមានរំលោភ ឲ្យលុយដើម្បីបញ្ចប់រឿងតែជនរងគ្រោះមិនព្រម ស្រាប់តែបោះពាក្យថា «បើមិនយកទៅប្តឹងអ្នកណាក៏ទៅៗ» ពេលជនរងគ្រោះទៅដាក់ពាក្យបណ្តឹងប៉ូលិសក៏គេមិនទទួល | | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៥ | https://tvfb.news/article/26424?fbclid=IwAR3flrj5dGVKBdhdF_qEWXJuR6zYkI2EEHKOeqNaEZ3O55Ib4FvLhxkAXuE | មិនមានឈ្មោះ | តុលាការ សម្រេចឃុំខ្លួនឃាតកជាប្តីដែលសម្លាប់ប្រពន្ធ រួចចាក់សាំងដុតក្នុងផ្ទះ បង្វែរដានទៅជាករណីអគ្គិភ័យ ដាក់ពន្ធនាគារបណ្តោះអាសន្នហើយ! | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ រូបថត) | មិនមានបញ្ហា | មិនមានបញ្ហា |
| ១៦ | https://tvfb.news/article/24003 | មិនមានឈ្មោះ | ព្រោះតែភ្លើងប្រចណ្ឌ ស្ត្រីម្នាក់ ត្រូវបុរសជាប្តី បានយកកណ្តៀវមកកាប់ បណ្តាលឲ្យរបួសធ្ងន់ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញា (ឈ្មោះ និងរូបភាព) | យកហេតុផលប្រច័ណ្ឌជាលេសនៃការកាប់ប្រពន្ធ | មិនមានបញ្ហា |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | https://tvfb.news/article/25510 | មិនមានឈ្មោះ | ឥទ្ធិពលគ្រឿងញៀន និងភ្លើងប្រចណ្ឌ ប ណ្តាលឲ្យប្តីកាប់សម្លាប់ប្រពន្ធ រួចចងក ខ្លួនឯងជាក្រោយ | បង្ហាញអត្តសញ្ញាណជនរងគ្រោះ និងជនមុខសញ្ញាណ (ឈ្មោះ) បង្ហាញរូបភាពនៃការស្លាប់ | យកហេតុផលគ្រឿង ញៀន និងភ្លើងប្រច័ណ្ឌជា លេសនៃការសម្លាប់ប្រពន្ធ | មិនមានបញ្ហា |
| ១៨ | https://www.facebook.com/TVOfficialChannel/videos/539454713491713/?v=539454713491713 | មិនមានឈ្មោះ | ចាប់វាយខ្ទេះបុរសជនជាតិចិនម្នាក់ ក្រោយតណ្ហាពុះកញ្ជ្រោលលូកលាន់នាង | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព) | យកបញ្ហាតណ្ហាពុះក ញ្ជ្រោលជាលេសនៃការ បៀតបៀន | មិនមានបញ្ហា |
| ១៩ | https://tvfb.news/article/26440?fbclid=IwAR0ZndGiDW95HV0nxPX9_DgM2b2JwIdoNZwOQptt3X0OuD4jPA9VZhxIp-o | មិនមានឈ្មោះ | ឪចុងចិត្តអប្រិយ រំលោភកូនស្រីអាយុ១៣ ឆ្នាំ... | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (រូបភាព ឈ្មោះ) | មិនមានបញ្ហា | មិនមានបញ្ហា |
| ២០ | https://tvfb.news/article/26611?fbclid=IwAR0S-BDj1yk7gn46KTMhGxnjhFyIQNlMdBTzpUVIinca90bl-JrAewREycE | មិនមានឈ្មោះ | កុំចេះតែចង់ គុកចឹង!!! កំពុងតែដេកក្នុង បន្ទប់ផ្ទះជួល ស្រាប់តែបុរសអ្នកជិតខាង កាន់ដាវមកគោះទ្វារ គម្រាមសម្លាប់ រួច ចូលចាប់រំលោភបានសម្រេច | បង្ហាញអត្តសញ្ញាណជនមុខសញ្ញា (ឈ្មោះ រូបភាព) | មិនមានបញ្ហា | មិនមានបញ្ហា |

## យេនឌ័រ និងសារព័ត៌មាន
## កាត់បន្ថយ ឬលុបបំបាត់ អំពើហិង្សាលើស្ត្រី
## តួនាទីដ៏មានតម្លៃរបស់បណ្ដាញសារព័ត៌មាន

| | |
|---|---|
| **ជនល្មើស** | • អ្នកប្រព្រឹត្តខុស ឱ្យរាងចាល និងទទួលទោស<br>• គ្មានវប្បធម៌លើកលែងទោស និងគ្មានលេស |
| **អាជ្ញាធរមានសមត្ថកិច្ច** | • អនុវត្តតាមដែនសមត្ថកិច្ចរបស់ខ្លួន ដោយ មិនមាន វប្បធម៌លើកលែងទោស<br>• លើកទឹកចិត្ត និងជួយជនរងគ្រោះ ទទួលភាពយុត្តិធម៌ |
| **សហគមន៍ និងសង្គម** | • ជួយជំរុញឱ្យសង្គម ផ្ដល់កម្លាំងចិត្ត និងគាំទ្រដល់ ជនរងគ្រោះ ជៀសវាង រើសអើង ឬដាក់បន្ទុក<br>• អំពើហិង្សាលើស្ត្រី ជារឿងមិនអាចអត់ឱនបាន |
| **ជនរងគ្រោះ** | • មិនក្លាយជាជនរងគ្រោះបន្ថែម និងទទួលបានយុត្តិធម៌ (រាយការណ៍ មិនប៉ះពាល់ដល់កិត្តិយស និងរងគ្រោះបន្ថែម) |

(ដកស្រង់ចេញពីបទបង្ហាញរបស់ ឯកឧត្ដម ថេរ ឈុនហាក់ អគ្គនាយក នៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី)